## អ្វីទៅជាជំនួយគូសាណូណេ?

គូសាណូណេគឺជាជំនួយដែលផ្តល់ជូនសម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍នានានៅកម្រិតមូលដ្ឋាន។ នៅឆ្នាំ២០០៣ ពាក្យ "សន្តិសុខមនុស្សជាតិ" ត្រូវបានបន្ថែមដើម្បីឲ្យស្របនឹងគោលគំនិតដែល៖

-មិនគ្រាន់តែជួយជំរុញបុគ្គល និងសហគមន៍ឲ្យម្ចាស់ការលើខ្លួនឯងប៉ុណ្ណោះទេ

-ប៉ុន្តែក៏ដើម្បីការពារប្រជាជនពីកត្តាជាច្រើនដែលគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិផងដែរ។

ថវិកាជំនួយអតិបរមាសម្រាប់គម្រោងនិមួយៗគឺ១០លានយ៉េន។

ថវិកាគម្រោងអាចប្រើប្រាស់សម្រាប់ការទិញ ឬសាងសង់សំណង់ និងសម្ភារៈ។

### សម្ភារៈទាំងនេះមិនត្រូវបានផ្តល់ជូនដោយជំនួយនេះឡើយ៖

-ការចំណាយផ្នែករដ្ឋបាលរបស់ស្ថាប័នស្នើសុំជំនួយ ដូចជា ការជួលការិយាល័យ និងប្រាក់ខែរបស់បុគ្គលិក

-ការចំណាយលើសេវាកម្មប្រតិបត្តិ ឬការថែទាំអាគារ និង សម្ភារៈផ្សេងៗ

-មុខចំណាយដែលជាកម្មសិទ្ធិរបស់បុគ្គល

-របស់ប្រើប្រាស់ និងសម្ភារៈតូចតាច

-សៀវភៅ និង កុំព្យូទ័រផ្ទាល់ខ្លួន

-យានយន្ត ដីធ្លី និងពន្ធដារ ឬ កម្រៃជើងសារធនាគារ

### ស្ថាប័នមានសិទ្ធិទទួលជំនួយ

✓

(បុគ្គល និង អង្គការស្វែងរកប្រាក់កម្រៃមិនមានសិទ្ធិក្នុងការដាក់ពាក្យឡើយ)

✓ <u>អាជ្ញាធរមូលដ្ឋាន</u>

(ក្រសួងមិនមានសិទ្ធិដាក់ពាក្យសុំទេ)

✓ <u>អង្គការមិនស្វែងរកកម្រៃនានា</u>

មានដូចជា មន្ទីរពេទ្យ និង សាលាបឋមសិក្សា

➢ ស្ថាប័នដាក់ពាក្យសុំត្រូវមានបទពិសោធន៍យ៉ាងតិចបំផុតពីរ (២) ឆ្នាំនៅក្នុងវិស័យដែលបានលើកគម្រោងសំណើ

➢ ស្ថាប័នដាក់ពាក្យសុំក៏តម្រូវឲ្យបង្ហាញពីសមត្ថភាព និងបទពិសោធន៍ពីមុនៗក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ បុគ្គលិក និងគម្រោងផ្សេងៗ។





➢ វិស័យអប់រំ
grassroots1.jpn@pp.mofa.go.jp

➢ វិស័យសុខាភិបាលនិង ទឹកស្អាត
grassroots2.jpn@pp.mofa.go.jp

➢ វិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ
grassroots4.jpn@pp.mofa.go.jp

☎023-217-161 (ផ្នែកជំនួយគូសាណូណេ)

គេហទំព័រ៖
http://www.kh.emb-japan.go.jp/economic/cooperation/cooperation.htm

ទំព័រហ្វេសប៊ុក៖
https://www.facebook.com/JapanEmbassyCambodia



# KUSANONE GRANT 2015




Japan-Cambodia Kizuna Event

# ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

# ផែនទីបង្ហាញទីតាំងគម្រោងជំនួយគូសាណូណេ

## វិស័យអប់រំ

①គម្រោងសាងសង់អគារសិក្សានៅសាលាបឋមសិក្សាប៉ោយអង្គរ និងសាលាបឋមសិក្សាខ្វាយ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

②គម្រោងសាងសង់អគារសិក្សានៅអនុវិទ្យាល័យភ្នំធំ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ

③គម្រោងសាងសង់អគារសិក្សានៅសាលាបឋមសិក្សាអង្គរអង្គ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

④គម្រោងសាងសង់អគារសិក្សានៅអនុវិទ្យាល័យតាកែវ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

⑤គម្រោងកែលម្អបរិក្ខារអនាម័យនៅសាលាបឋមសិក្សា៦ នៃស្រុកកងមាស និងស្រុកបាធាយ ខេត្តកំពង់ចាម

⑥គម្រោងកែលម្អបរិស្ថាននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យច្រកត្នោត ខេត្តកំពង់ឆ្នាំង

⑦គម្រោងសាងសង់អគារសិក្សានៅអនុវិទ្យាល័យព្រែកកំពឹស រាជធានីភ្នំពេញ

⑧គម្រោងសាងសង់អគារសាលាមត្តេយ្យចំនួន៣ក្នុងស្រុកកោះធំ និងស្រុកអង្គស្នួល ខេត្តកណ្តាល

⑨គម្រោងសាងសង់អគារពហុប្រយោជន៍ជាមួយសាលវិទ្យាសាស្ត្រនៅសាលាគរុកោសល្យ និងវិក្រឹត្យការខេត្តក្រចេះ

## វិស័យសុខាភិបាល

⑩គម្រោងសាងសង់អគារជំងឺទូទៅក្នុងមន្ទីរពេទ្យបង្អែកជើងព្រៃ ខេត្តកំពង់ចាម

⑪គម្រោងសាងសង់មណ្ឌលសុខភាពខុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប

⑫គម្រោងបំពាក់ម៉ាស៊ីនជំនួយការដកដង្ហើមក្នុងមន្ទីរពេទ្យកុមារអង្គរ ខេត្តសៀមរាប

⑬គម្រោងសាងសង់អគារជំងឺទូទៅ និងកុមារក្នុងមន្ទីរពេទ្យបង្អែកព្រែកប្បាស ខេត្តតាកែវ

⑭គម្រោងកែលម្អអគារវះកាត់ក្នុងមន្ទីរពេទ្យបង្អែកពារាំង ខេត្តព្រៃវែង

⑮គម្រោងកែលម្អសុខភាពមាតា និងទារកតាមរយៈការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលក្នុងខេត្តកំពង់ស្ពឺ




◎រយៈពេលអនុវត្តគម្រោង៖ ១ ឆ្នាំ
◎គម្រោងចំនួន២២ ដែលមានទឹកប្រាក់ប្រមាណ២លាន៣សែនដុល្លារអាមេរិកត្រូវបានអនុម័តក្នុងឆ្នាំសារពើពន្ធ ២០១៣
(ឆ្នាំសារពើពន្ធជប៉ុន៖ ១មេសា - ៣១មិនា)

## វិស័យទឹកស្អាត

⑯គម្រោងតំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងកែប និងស្រុកដំណាក់ចង្អើរ ខេត្តកែប

## វិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ

⑰គម្រោងស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រកំពែង ខេត្តពោធិ៍សាត់ (ដំណាក់កាលទី២)

⑱គម្រោងស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រដូងក្នុងខេត្តកំពង់ចាម

⑲គម្រោងស្តារឡើងវិញប្រឡាយមុខបួន ខេត្តបាត់ដំបង

⑳គម្រោងស្តារឡើងវិញប្រឡាយលេខ៧ ខេត្តសៀមរាប

㉑ គម្រោងកែលម្អប្រព័ន្ធលូរំដោះទឹកតាមបណ្តោយផ្លូវជាតិលេខ៥ ក្នុងខេត្តបាត់ដំបង

㉒ គម្រោងសាងសង់កំពង់ចម្លងកំពង់ស្រឡៅ១ ខេត្តព្រះវិហារ




**តាមវិស័យ**




**តាមប្រភេទស្ថាប័ន**

គម្រោងដែលត្រូវបានអនុម័តពីថ្ងៃទី១ មេសា ឆ្នាំ ២០១៣ ដល់ ថ្ងៃទី៣១ មិនា ឆ្នាំ ២០១៤